ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២០-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៣៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្តម ច័ន្ទ ឡឿន ២៣១០

២០-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៣៩ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះលោក ម៉ាខ ម៉ាន់ថា និងលោកវរសេនីយ៍ឯក ប្រាក់ ចាំ ២៣១១

២១-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤០ ស្តីពីការតម្លើងឋានៈ ជូនជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ចំនួន ០២ រូប ២៣១២

២១-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤១ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំពោះឯកឧត្តម,លោកជំទាវនិងអស់លោកចំនួន២៣រូប ២៣១៣

២១-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤២ ស្តីពីការតែងតាំងឯកឧត្តម សុត រស្មី ជាជំនួយការ ខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក ២៣១៥

២៦-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៤ ស្តីពីការតែងតាំងឯកឧត្តម ម៉ៅ ភន ជាឧកញ៉ា ២៣១៦

២៦-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៥ ស្តីពីការតែងតាំងឯកឧត្តម ឌិម គីលី ជាទីប្រឹក្សា ឯកឧត្តម ខួន ញឹល អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ២៣១៧

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និងអស់លោក ចំនួន ២៩ រូប ២៣១៨

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៧ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី សោម ឡាញ់ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ២៣២០

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៨ ស្តីពីការកែសម្រួលមាត្រា ១ និងមាត្រា ៦ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការ បង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ២៣២១

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៤៩ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាជាតិអប់រំ ២៣២៤

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៥០ ស្ដីពីការតែងតាំងឯកឧត្ដម **ហ៊ាន ម៉ុនឆៀង** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ២៣២៧

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៥១ ស្ដីពីការតែងតាំងឯកឧត្ដម **អ៊ុន នឹម** ជាអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២៣២៨

២៧-៣-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣៥២ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,អស់លោកនិងលោកស្រីចំនួន ១៤ រូប ២២២៩

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៦-៤-២០០៩ -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្ដីពីការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច ២៣៣០

០៦-៤-២០០៩ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ២៣៣៣

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ២៣៤១

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៤៦

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្ដីពីការតម្លើងឋានៈ និងតែងតាំងមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន ២៣៤៧

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៣៤៨

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៣៥០

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៥១

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៥២

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៦១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៣៥៣

២៤-៣-២០០៩ -អនុក្រឹត្យលេខ ៤៦២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៣៥៥

២៥-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៥៧

២៥-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៤ អនក្រ.តត ស្ដីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន ២៣៥៨

២៥-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៥ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៣៥៩

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៦១

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣៦២

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៣៦៣

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៦៩ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ ២៣៦៤

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៧០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៣៦៥

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៧១ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៦៦

២៦-៣-២០០៩ -អនុក្រឹត្យលេខ ៤៧២ អនក្រ.តត ស្ដីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ
ក្រសួងមហាផ្ទៃ ២៣៦៧

## ២_សេចក្ដីសំរេច

០៦-៤-២០០៩ -សេចក្ដីសំរេចលេខ ២៣ សសរ ស្ដីពីការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះ
រាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ លើវិស័យមីន ២៣៧២

## III_ការងារបណ្ដាក្រសួង

## ១_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៣០-៣-២០០៩ -ប្រកាសលេខ ២០៦ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីកូ (ខេមបូឌា) ខូអិលធីឌី
បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់" ២៣៧៤

៣០-៣-២០០៩ -ប្រកាសលេខ ២២៩ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជីង សៀង អ៊ីនដាសស្ទ្រី
(ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរ និងបោកគក់ សម្លៀកបំពាក់" ២៣៧៩

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

០៦-៤-២០០៩ -សេចក្ដីជូនដំណឹងលេខ ០២៤/០៩ កប/សជណ ស្ដីពីការប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៣
ទិវាពលកម្មអន្តរជាតិ ២៣៨៤

## ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៤៩២ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទីហ្វូឡាយហ្វ៍ មេឌា ស៊ីលូសិន អេជេនស៊ី** ២៣៨៦

១៤-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៤៥៥ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាចត្រូន ខបភើរេសិន** ២៣៨៨

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៥៩២ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដេដាប់ប៊ែលយូ (ខេមបូឌា) អ៊ីខូ ហ្វូលីដេ** ២៣៩០

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៥៩៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខ្វូ អាម (ខេមបូឌា) ២៣៩២

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៥៩៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ថេសង់ អេឡិក្ត្រិខលឃ័រ ២៣៩៤

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៥៩៥ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីុខ ត្រាវ៉ែល & ធួរ ២៣៩៦

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៦០៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌី.ស៊ី មេគន្ត អ៊ិនវេសមេន ២៣៩៨

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៦០៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អម្រិត រូបរឿង គ្រុប លីមីធីត ២៤០០

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៦១០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ភ្នំដិន អ៊ិនដាសស្រ្ទៀល ឌីវេឡុបមេន ២៤០២

២១-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៦១១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ធីមស្ទួ អិម & អ៊ី ២៤០៤

២៨-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៧៥៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន លាន ហេង ម៉ាញូនីង ខូ អិលធីឌី ២៤០៦

២៨-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៧៦០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គ្លូប៊ល ហ្គោម អ៊ិនធើណេសិនណាល ខូ អិលធីឌី ២៤០៨

២៨-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៧៦១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ៊ុង ម៉ៃ (ឡេវ ប៊ុន) គ្រុប អ៊ិនវេសមេន (ខេមបូឌា) ២៤១០

២៨-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤៧៦៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន លីម ឆាយ ត្រេនស្ព័ត & ត្រេឌីង ២៤១២

នស/រកត/០៣០៩/៣៣៩

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

ឯកឧត្តម ចំនួ ឌៀន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ៧.០៩០៣.៣៤១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩

លេខ ៥៦៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានឧកមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-លោក ជឹង ចាន់ថា

២-លោកវរសេនីយ៍ឯក ថ្លាក់ ចាំ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៩០៣.៣៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩

លេខ : ២៩៧ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible]៤ ខែ មិនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានៈជូនជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម :

១- លោកជំទាវ ជា សុផាម៉ាដែន

២- លោកជំទាវ យឹម ឆៃលីន

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៣.៣៤៣

លេខ : ៣០៦ ច.ល

សម្រាប់ចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-ឯកឧត្តម **លី គីមសុខ**

២-ឯកឧត្តម **ទ្រី មេង**

៣-ឯកឧត្តម **ស៊ីម សុន**

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-ឯកឧត្តមបណ្ឌិត **ចាន់ជារ៉ុង**

២-ឯកឧត្តម **សៅ ជីវន្ត័**

៣-ឯកឧត្តម **លន់ គុន**

៤-ឯកឧត្តម **ប៊ុន ច័ន្ទវណ្ណៈ**

៥-ឯកឧត្តម **សេង លីម៉េង**

៦-ឯកឧត្តម **ហួត សារីម**

៧-ឯកឧត្តម **សាន វិសាល**

៨-លោកបណ្ឌិត **ថេង ច័ន្ទសង្វារ**

៩-លោក **សាម សាឃ**

១០-លោក **សុត រស្មី**

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | |
|---|---|---|
| ១-ឯកឧត្តម | **ឡឹក** | **ជុលណាល់** |
| ២-លោកជំទាវ | **ជាំ** | **ដារីនី** |
| ៣-ឯកឧត្តម | **ថោង** | **ពោធ** |
| ៤-ឯកឧត្តម | **លី** | **ស៊ីមអ៊ាម** |
| ៥-លោក | **ទ៉ាន់** | **ម៉ូលុយ** |
| ៦-លោក | **ហេង** | **សុខអេង** |
| ៧-លោក | **ម៉ា** | **ហ៊ូឌី** |

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោក | **នួន** | **ដានីញ៉ៀល** |
| ២-លោក | **ដារ៉ា** | **មង្គល** |
| ៣-លោក | **ជុន** | **លីមហាន** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៩០៣.៣៤៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៩*

លេខ : ៣០៧ ច.ល
**ជូនចំលងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤២

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្ដម សុខ រស្មី ជាជំនួយការខុទ្ទកាល័យសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២ :** សម្ដេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣រល.០៩០៣.៣៤៥

លេខ : ៣០៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០០៩

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៣០៩/៣៤៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

ឯកឧត្តម ម៉ៅ ភន

ជា

## ឧកញ៉ា

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣/ល.០៩០៣.៣៤៧

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ: ៣៤៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី ៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ ២០០៩ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម ខិម ភីលី ជាទីប្រឹក្សាឯកឧត្តម ខួន ញ៉ុល អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រល.០៩០៣.៣៤៧

លេខ : ៣៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ០៧ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ានកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**
  - -ឯកឧត្តម **ឡោក ហ៊ួរ**
- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**
  - -ឯកឧត្តម **ជា សៀន**
- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**
  - ១.-ឯកឧត្តម **ហុង ពីវ**
  - ២-ឯកឧត្តម **ឡុច សារ៉េត**
  - ៣-ឯកឧត្តម **ជួន សុវណ្ណ**
  - ៤-ឯកឧត្តម **ឆ បូណារី**
  - ៥-ឯកឧត្តម **ឆោម សុភ័ក្ត្រ**
  - ៦-ឯកឧត្តម **ឈុន អូន**
  - ៧-ឯកឧត្តម **ប្រាក់ ចំរើន**
  - ៨-ឯកឧត្តម **មាស ប៉ូ**
  - ៩-លោកជំទាវ **ឆោម សោភ័ណ្ឌី**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

- ១-ឯកឧត្តម **ម៉ៅ តន**
- ២-ឯកឧត្តម **សែម គីថាយ**
- ៣-ឯកឧត្តម **សេង ចំរើន**
- ៤-ឯកឧត្តម **ហ៊ូ ជេហូ**
- ៥-លោក **ជួន ណារិន**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

-ឯកឧត្តម **ហ៊ាន ម៉ុនធឿន**

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១-ឯកឧត្តម **តោ វីរូ**

២-ឯកឧត្តម **សុខ ចាន់មុនី**

៣-ឯកឧត្តម **ស្រេង គង់**

៤-លោក **ចិន សំអាត**

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សប្បឬទ្ធិ**

១-ឯកឧត្តម **ហ៊ាង សេរីវុឌ្ឍ**

២-ឯកឧត្តម **ទេស សុខមេន**

៣-ឯកឧត្តម **ឃឹម ស៊ុនសូដា**

៤-ឯកឧត្តម **លឹម ហ៊្សូរនីតា**

៥-លោក **សុខ សុគន្ធ**

៦-លោក **សោ ផាន់ណូ**

៧-លោក **លី សុខន**

៨-លោក **ម៉ែន គីមហួង**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩ល.០៩០៣.៣៤៩

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៣២៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **សោម ឡាញ់** អត្តលេខ ០៣១០ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ មីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រល. ០៩០៣. ៣៥០

លេខ : ៣៤៧ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៧

## ស្តីពី

## ការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើត ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនាឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩

# ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា១ និងមាត្រា៦នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានធ្វើការកែសម្រួលដូចតទៅ :

**មាត្រា ១ .- ថ្មី**

ត្រូវបានបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីបំពេញបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋលើវិស័យច្បាប់ និងយុត្តិធម៌ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | | សហប្រធាន |
| - ប្រធានតុលាការកំពូល | | សហប្រធាន |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | អនុប្រធាន |
| - ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | | អនុប្រធាន |
| - ប្រធានសាលាឧទ្ធរណ៍ | | អនុប្រធាន |
| - ប្រធានសាលាដំបូងរាជធានីភ្នំពេញ | | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១រូប | សមាជិក |
| - អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | | សមាជិកអចិន្ត្រៃយ៍ ។ |

ការតែងតាំងសមាសភាព នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

**មាត្រា ៦ .- ថ្មី**

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។



ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រាពីរ ៈ**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី ៈ**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

*នស/រកត.០៣០៣.៣៥៦*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៣៧៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible]៧ ខែ មេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៩

## ស្តីពី
## ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត **ឧត្តមក្រុមប្រឹក្សាជាតិអប់រំ** ជាស្ថាប័នថ្នាក់ជាតិទទួលខុសត្រូវ នយោបាយអប់រំ ចំពោះមុខរាជរដ្ឋាភិបាល ដែលសរសេរជាអក្សរកាត់ថា**ឧ.ក.ជ.អ.** ។

## ជំពូកទី២

## សមាសភាព

**មាត្រា ២.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានសមាសភាពដូចខាងក្រោម ÷

- នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន
- ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារអប់រំ អនុប្រធាន
- ឥស្សរជនមួយរូប អនុប្រធាន
- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី មួយរូបជាសមាជិក
- ប្រធាន ឬ អនុប្រធាននៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល មួយរូបជាសមាជិក
- ប្រធាន ឬ អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងផែនការ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មួយរូបជាសមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងធម្មការ និងសាសនា មួយរូបជាសមាជិក



- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ មួយរូបជាសមាជិក
- ឥស្សរជន ដែលមានបទពិសោធខាងអប់រំ នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ មួយចំនួនជាសមាជិក

## ជំពូកទី ៣
## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្រ រយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ច របស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល
- វាយតម្លៃការងារដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧.០៣០៣.៣៥២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៣៤០ ច.ល

[illegible] ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម **ហ៊ាន ម៉ុនឆៀវ** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៧៧.០៩០៣.៣៥៣

លេខ : ៣១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម **អ៊ុន ឆឹម** ជាអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រល.០៩០៣.៣៥៤

លេខ : ៣១៣ ច.ល
ថតចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ប៊ុន ឆិនកេន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៣០៩/៣៥៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
  - ឯកឧត្តម ទី សុគន្ធ
- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | |
|---|---|
| ១-ឯកឧត្តម ឡោ ស្មើ | ៥-លោក ជឹម ខួន |
| ២-ឯកឧត្តម ចាន់ ណារ៉េត | ៦-លោក ទៅ ម៊ុនថាន |
| ៣-ឯកឧត្តម លី ផល្លា | ៧-លោក ខឹម ចិន្តា |
| ៤-ឯកឧត្តម ណៅ ធូក | ៨-លោក ផាន់ មុនី |

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

| | |
|---|---|
| ១-ឯកឧត្តម ឡុង ឈាង | ៤-លោក ហេង សារ៉ាត់ |
| ២-លោក ម៉ែន សារុម | ៥-លោក ចាន់ ហ៊ិត |
| ៣-លោកស្រី ចាន់ ផលលឿន | |

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩*

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

៣រល.០៩០៣.៣៥៥

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ ៣៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០០២ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថាន ឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលមានអក្សរកាត់ "វ.អ.ស" ត្រូវនឹងភាសាអង់គ្លេសថា ( INSTITUE FOR DEVELOPMENT OF ECONOMY ) មានអក្សរកាត់ ( IDE ) ។ វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមានទីតាំងស្ថិតនៅអគារលេខ ១២-១៤បេ ផ្លូវលេខ ២៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចមានភារកិច្ចធ្វើការបណ្តុះបណ្តាល :

-ថ្នាក់វិញ្ញាបនបត្រ បណ្តុះបណ្តាលរយៈពេលខ្លីក្រោម ១ឆ្នាំ ទៅតាម ជំនាញវិជ្ជាជីវៈ ។

-ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ។

-ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ។

-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ។

**មាត្រា ៣ :** ចំពោះមុខវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច មានរចនាសម្ព័ន្ធដូចខាងក្រោម :

១- ការិយាល័យសិក្សា

២- ការិយាល័យរដ្ឋបាល

៣- ការិយាល័យបច្ចេកទេស

៤- ការិយាល័យផែនការ និងហិរញ្ញវត្ថុ

៥- ដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម

៦- ដេប៉ាតឺម៉ង់នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ

៧- ដេប៉ាតឺម៉ង់ភាសាបរទេស

៨- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

៩- ដេប៉ាតឺម៉ង់សណ្ឋាគារ និងទេសចរណ៍

១០- ដេប៉ាតឺម៉ង់គណនេយ្យ-ធនាគារ

១១- ដេប៉ាតឺម៉ង់ព័ត៌មានទីផ្សារ

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកដេប៉ាតឺម៉ង់ ឬសាខា ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន :

- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនទាំង ២ភេទ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កំរិត ៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនទាំងពីរភេទ មានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បេក្ខជនទាំង ២ភេទ ត្រូវមានសញ្ញាបត្រវិស្វករ ឬបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀនតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៥ :** វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចមាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៧ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងនាយិកាវិទ្យាស្ថាន អភិវឌ្ឍន៍សេដ្ឋកិច្ចមានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ក្រសួងអប់រំយុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- គ្រប់ខេត្ត-ក្រុង
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៥៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- លើកសំណើជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពិនិត្យ និងសម្រេចអំពីទស្សនាទានគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- ទាក់ទង សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីការងារធ្វើឱ្យបានសម្រេច គោលដៅទាំងឡាយនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដាក់ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ពិនិត្យ និងសម្រេច

- តាមដានការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតាមបណ្តាក្រសួងស្ថាប័នអនុវត្តនានា និងស្ថាប័នតុលាការ និងធ្វើរបាយការណ៍បូកសរុបលទ្ធផល ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- ធ្វើការសម្របសម្រួលជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាដៃគូឱ្យបានរឹងមាំ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការដែលមានអគ្គលេខាធិការ នៃក្រុមប្រឹក្សា-កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាប្រធាន ឬតាមរយៈយន្តការផ្សេងទៀត

- ផ្តល់ជូនក្រសួងស្ថាប័នរដ្ឋ តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួននូវបង្អែកបច្ចេកទេសចាំបាច់

- រៀបចំផែនការកម្ម ដាក់ឱ្យដំណើរការ សម្របសម្រួល និងវាយតម្លៃលើគ្រប់គម្រោងដែលមាននៅក្នុងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ

សម្រាប់ដំណើរការអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- រៀបចំកម្មវិធី និងបង្កើតយន្តការការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង

- រៀបចំកម្មវិធីពង្រឹងការផ្តល់សេវាកម្មយុត្តិធម៌ដែលមានឯករាជ្យ ការជឿទុកចិត្ត តម្លាភាព និងការទទួលខុសត្រូវខ្ពស់របស់ចៅក្រម និងមន្ត្រីយុត្តិធម៌ផ្សេងទៀតឱ្យដល់ប្រជាពលរដ្ឋគ្រប់រូប

- រៀបចំយន្តការជំនួយផ្នែកច្បាប់ឱ្យមានគុណភាពខ្ពស់ និងគ្រប់គ្រាន់សម្រាប់ជួយដល់ជនក្រីក្រ.

- ជំរុញឱ្យមានប្រព័ន្ធសម្រាប់អនុវត្តសេចក្តីសម្រេចរបស់តុលាការឱ្យមានភាពប្រសើរឡើង

- ជំរុញឱ្យមានមូលដ្ឋានទិន្នន័យ នៃសេចក្តីសម្រេចរបស់តុលាការពីមុនៗមក

- ជំរុញឱ្យមាននីតិវិធី និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានដល់ថ្នាក់ឃុំ សង្កាត់

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- អាចអញ្ជើញឥស្សរជនជាតិដែលមានគុណសម្បត្តិ និងបទពិសោធន៍ខ្ពស់មកចូលរួមប្រជុំពិគ្រោះយោបល់

- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ប្រគល់ឱ្យ ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានមន្ត្រីបម្រើការមកពីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការ អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា សម្រាប់បម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានបាន ។ មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភផ្សេងៗក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីក្នុងកិច្ចដំណើរការការងាររបស់ខ្លួន ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានរចនាសម្ព័ន្ធដូចខាងក្រោម :

- ផ្នែករដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ

- ផ្នែកកំណែទម្រង់ច្បាប់

- ផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្នែកលើកកម្ពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
- ផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា។

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបានតាមការចាំបាច់។

អង្គការលេខ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ផ្នែក

### មាត្រា ៧.-

ផ្នែករដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មាន តួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើការងារគ្រប់គ្រងរដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុរួមទាំងការគ្រប់គ្រង និងធ្វើឱ្យចរាចរលិខិត ឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងឯកសារទូទាត់ថវិកា ផ្គត់ផ្គង់សម្ភារៈ ភស្តុភារ គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលអំពីការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ។

### មាត្រា ៨.-

ផ្នែកកំណែទម្រង់ច្បាប់មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ ជំរុញ និងកែលំអក្របខ័ណ្ឌច្បាប់ ដោយសហការជាមួយក្រសួងស្ថាប័នរដ្ឋ
- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំនីតិវិធីនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាឱ្យកាន់តែប្រសើរឡើង
- លើកគម្រោង និងចូលរួមធ្វើការអប់រំផ្សព្វផ្សាយច្បាប់
- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ នៅតាម ក្រសួងស្ថាប័នពាក់ព័ន្ធ

- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ៩.-**

ផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ លើកគម្រោងកែលំអ ពង្រឹងសេវាយុត្តិធម៌ឱ្យមានឯករាជ្យ តម្លាភាព ជំនឿទុកចិត្ត និងការទទួលខុសត្រូវខ្ពស់
- សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីបង្កើនគុណភាពការផ្តល់ជំនួយសេវាផ្នែកច្បាប់ដល់ជនក្រីក្រ ការអប់រំ និងការបណ្តុះបណ្តាល
- សិក្សាស្រាវជ្រាវ និងចូលរួមរៀបចំកម្មវិធីធ្វើឱ្យប្រសើរឡើង ប្រព័ន្ធសម្រាប់អនុវត្តសេចក្តីសម្រេចរបស់តុលាការ និងជំរុញឱ្យមានមូលដ្ឋានទិន្នន័យ នៃសេចក្តីសម្រេចរបស់តុលាការពីមុនៗមក
- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅតាមស្ថាប័នពាក់ព័ន្ធ
- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១០.-**

ផ្នែកលើកកម្ពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំកម្មវិធីបង្កើតយន្តការ និងពង្រឹងការលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ
- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំនីតិវិធី និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ
- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១១.-**

ផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ លើកគម្រោងកែលំអ ធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មានក្នុងវិស័យច្បាប់ និងតុលាការ
- ប្រមូលចងក្រង ទុកដាក់ ធ្វើសមទិន្នព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំអត្ថបទ និងបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្ររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាដល់គ្រប់ផ្នែក នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កសាងមូលដ្ឋានទិន្នន័យច្បាប់ និងប្រមូលទិន្នន័យច្បាប់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទាក់ទងនឹងបញ្ហាព័ត៌មាន

-អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៣.-**

មន្ត្រីបម្រើការនៅអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវផ្ទេរទាំងតួនាទី ទាំងភារកិច្ច ឱ្យទៅបម្រើការនៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

អនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហាឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២១ ខែ សីហា ឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន

មុខងារសាធារណៈ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមនិងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៥៣ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣ និងមាត្រា៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា១១ថ្មី នៃព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួល ស្គាល់គុណភាពអប់រំនៃកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

# សម្រេច

**មាត្រាមួយ.-**

មាត្រា៣ មាត្រា៤ មាត្រា៧ និងមាត្រា៨ នៃ អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (**គ.ឧ.ក**) ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

**មាត្រា៣ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** ជាអង្គភាពប្រតិបត្តិ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គលេខាធិការរងមានភារកិច្ចទទួលខុសត្រូវតាមការចាត់តាំងរបស់អគ្គលេខាធិការ ។

**មាត្រា៤ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

១. នាយកដ្ឋាន កិច្ចការទូទៅ

២. នាយកដ្ឋាន ស្ដង់ដារ និងការទទួលស្គាល់គុណភាពអប់រំ

៣. នាយកដ្ឋាន សហប្រតិបត្តិការ និងព័ត៌មាន

៤. នាយកដ្ឋាន ផែនការ បណ្ដុះបណ្ដាល និងស្រាវជ្រាវ

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ។ ការបង្កើត និងភារកិច្ចរបស់ការិយាល័យ ត្រូវសម្រេចដោយ **គ.ឧ.ក** តាមសំណើរបស់អគ្គលេខាធិការ ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **គ.ឧ.ក** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៧ថ្មី.-**

នាយកដ្ឋានស្ដង់ដារ និងការទទួលស្គាល់គុណភាពអប់រំមានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបង្កើត និងអភិវឌ្ឍស្ដង់ដារគុណភាពអប្បបរមា សម្រាប់វាយតម្លៃលើគ្រឹះស្ថានឧត្ដមសិក្សា
- រៀបចំបង្កើត និងអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានឧត្ដមសិក្សា និងសម្រាប់មន្ត្រីវាយតម្លៃ
- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន
- រៀបចំការចុះវាយតម្លៃ និងពិនិត្យឡើងវិញ លើដំណើរការទទួលស្គាល់គុណភាពអប់រំនៃកម្មវិធីសិក្សាដំណើរការបណ្ដុះបណ្ដាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងគ្រឹះស្ថានឧត្ដមសិក្សាទាំងមូល
- លើកសំណើជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្ដមសិក្សា
- ផ្ដល់ការពិគ្រោះយោបល់ដល់គ្រឹះស្ថានឧត្ដមសិក្សា លើដំណើរការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា

- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំផ្តល់ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា
- ធ្វើរបាយការណ៍ស្តីពី សកម្មភាព និង លទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន។

**មាត្រា៨ថ្មី.-**

នាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាន មានភារកិច្ច ដូចខាងក្រោម ៖

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងប្រទេសនានា ក្នុងការងារទូទៅពាក់ព័ន្ធនឹងការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងស្វែងរកជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ
- គ្រប់គ្រង និងចងក្រងទិន្នន័យព័ត៌មានគ្រប់ប្រភេទ របស់ **គ.ឧ.ក**
- ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលគំហើញ និងព័ត៌មានផ្សេងៗ របស់ **គ.ឧ.ក**
- រៀបចំកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ព័ន្ធនឹងការងាររបស់ **គ.ឧ.ក**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន។

**មាត្រាពីរ.-**

នាយកដ្ឋាន ផែនការ បណ្តុះបណ្តាល និងស្រាវជ្រាវ មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សនៃអគ្គលេខាធិការដ្ឋាន លើការងារបច្ចេកទេស ព័ត៌មានវិទ្យា ភាសាបរទេស និងជំនាញឯកទេសពាក់ព័ន្ធផ្សេងទៀត ទាំងក្នុងប្រទេស និង ក្រៅប្រទេស
- រៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីវាយតម្លៃ និង គ្រឹះស្ថានឧត្តមសិក្សា ពាក់ព័ន្ធនឹងយន្តការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ ការរៀបចំអភិវឌ្ឍកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការងារពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំគម្រោងបណ្តុះបណ្តាលផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងលើជំនាញពាក់ព័ន្ធនឹងការធានា និងទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- ធ្វើផែនការយុទ្ធសាស្ត្រ និងសម្របសម្រួលក្នុងការរៀបចំផែនការសកម្មភាពការងារ រយៈពេលខ្លី មធ្យម និង វែង របស់អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** ដើម្បីលើកកម្ពស់និងពង្រឹងគុណភាពអប់រំឧត្តមសិក្សា
- ស្វែងរកជំនួយពីដៃគូអភិវឌ្ឍ ជាតិ និង អន្តរជាតិ ដើម្បីទ្រទ្រង់កម្មវិធីបណ្តុះបណ្តាលនានា
- ពិគ្រោះយោបល់ជាមួយគ្រឹះស្ថានឧត្តមសិក្សានិងស្ថាប័នពាក់ព័ន្ធ អំពីការងារបច្ចេកទេស និងក្របខ័ណ្ឌគតិយុត្តផ្សេងៗ
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារគ្រប់ប្រភេទពាក់ព័ន្ធនឹងការទទួលស្គាល់គុណភាពអប់រំ ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ

- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន ។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ខែ ឆ្នាំ ២០០៩

# រចនាសម្ព័ន្ធ គ.ឧ.ក



# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៥៥៥ អនក្រ.តត**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនដល់សប្បុរសជន ចំនួន ០៨ រូប ដែលមានសទ្ធាជ្រះថ្លាបរិច្ចាគ ធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា ដូចជា កសាងព្រះវិហារ កុដិ របងក្លោងទ្វារ រោងទូកង និងសមិទ្ធផលជាច្រើនទៀត នៅវត្តស្លាកែត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានខាងក្រោម :-

| | | | | | |
|---|---|---|---|---|---|
| ១- | អ្នកស្រី | **ប៊ុន** | **ដានី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៧.០០០ ដុល្លារ |
| ២- | លោក | **តេ** | **ឡុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.០០០ ដុល្លារ |
| ៣- | លោក | **ទឹម** | **ស៊ឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៧.០០០ ដុល្លារ |
| ៤- | លោកតា | **សុខ** | **ក្រុក** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.៧០០ ដុល្លារ |
| ៥- | លោកជំទាវ | **ស៊ូ** | **ម៉ូរ៉ា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.៥០០ ដុល្លារ |
| ៦- | លោក | **ហ៊ួច** | **ពេញ** | សប្បុរសជននៅផ្សារគគីរ | ថវិកាចំនួន ១៦.១០០ ដុល្លារ |
| ៧- | ឧបាសក | **ទ្រី** | **សាម៉ាលី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៥.១០០ ដុល្លារ |
| ៨- | ឧបាសិកា | **ទ្រី** | **យក់ឡាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៥.១០០ ដុល្លារ |

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៥៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតម្លើងឋានៈ និងតែងតាំងមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

### សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានៈ និងតែងតាំងមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូនដូចខាងក្រោម :
១-លោក **ឈួន វិន** ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានរដ្ឋបាល
២-លោក **ស៊ឹម សុគន់** ជា **ប្រធាននាយកដ្ឋានផែនការ** ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ និងកុដិថ្មី នៅវត្តសុវណ្ណជលសារ ស្ថិតក្នុងឃុំជំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ទ័ត** | **ឃ្លាំង** | ព្រះចៅអធិការវត្តសុវណ្ណជលសារ | បច្ច័យ ចំនួន ១០.០០០ ដុល្លារ |
| ២-ឯកឧត្តមបណ្ឌិត | **ម៉េន** | **ស៊ីម៉ន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៣-លោក | **អ៊ុយ** | **ស៊ើង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៤-ឯកឧត្តម | **មាស** | **សុភា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | **អ៊ុន** | **ភុំ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១.៩០០ ដុល្លារ |
| ២-ឧបាសិកា | **ម៉ឹង** | **លន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១.៨០០ ដុល្លារ |
| ៣-ឧបាសិកា | **ម៉េង** | **មុំ** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០៣០ ដុល្លារ |
| ៤-ឧបាសក | **អ៊ួង** | **រិន** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |
| ៥-ឧបាសក | **នូ** | **ជឹម** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៦-ឧបាសក | **ទៀត** | **ឯម** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |
| ៧-លោក | **ញ៉េប** | **រដ្ឋា** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |
| ៨-លោក | **ស៊ួន** | **ហ៊ីង** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៥៨ - អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកែប

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហាន ចំនួន ០៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ឡាំ មេន** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប . |
| ២- | វរសេនីយ៍ឯក | **ខៀវ គុន** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៣- | វរសេនីយ៍ឯក | **នួន ផន** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៤- | វរសេនីយ៍ឯក | **ឃួន សុវណ្ណ** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៥- | វរសេនីយ៍ឯក | **ប៉ែន សំបូរ** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៦- | វរសេនីយ៍ឯក | **រ័ត្ន ធីម** | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៧- | អនុសេនីយ៍ឯក | **ស៊ូ សារុំ** | នាយរងការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៤៥៩- អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ស្ពឺ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេននិង ជូនព្រះសង្ឃ មន្ត្រីរាជការ ដែលមានស្នាព្រះហស្ថ និង ស្នាដៃល្អ ក្នុងការចូលរួមកសាង អភិវឌ្ឍន៍ ប្រទេសជាតិ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១- ព្រះតេជគុណ **គង់ ស៊ុក** ចៅអធិការវត្តត្រពាំងក្រពើ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្ត កំពង់ស្ពឺ

២- លោក **នុត សោភ័ណ្ឌ** អភិបាលរងស្រុកគងពិសី ខេត្តកំពង់ស្ពឺ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក វរសេនីយ៍ឯក **មៀច ហ៊ន** នាយរងការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅទីបញ្ជាការដ្ឋាន កងពលតូចអន្តរាគមន៍លេខ១៤ សម្រេចបានលទ្ធផលល្អ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១១ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៧១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកែប

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ១១ រូប ដែលបាន បរិច្ចាគ កម្លាំងកាយចិត្ត និងធនធានចូលរួមកសាង សមិទ្ធផលផ្សេងៗ នៅទីបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង ខេត្តកែប ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១ | លោក | **ឡាយ ផេង** | សមាជិកក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកែប និង ជាអាជីវករ |
| ២ | លោក | **ជា ម៉ឿន** | ក្រុមហ៊ុន មេកុងអេវ៉ិន |
| ៣ | វរសេនីយ៍ត្រី | **ឡុច សារ៉ែម** | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៤ | វរសេនីយ៍ត្រី | **កែវ ច័ន្ទថន** | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៥ | វរសេនីយ៍ត្រី | **សោម មុន្នី** | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៦ | វរសេនីយ៍ត្រី | **រស់ សុផាត** | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៧ | វរសេនីយ៍ត្រី | **យ៉ាង ផុក** | មេបញ្ជាការ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៨ | វរសេនីយ៍ត្រី | **ផន សុផល** | មេបញ្ជាការ ផ្នែកសឹករងស្រុកដំណាក់ចង្អើរ តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ៩ | វរសេនីយ៍ត្រី | **ខៀវ ម៉ុនរិទ្ធ** | មេបញ្ជាការ ផ្នែកសឹករងក្រុងកែប តំបន់ប្រតិបត្តិការសឹករងខេត្តកែប |
| ១០ | វរសេនីយ៍ត្រី | **ឯម សុនី** | នាយលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងខេត្តកែប |

១១ អនុសេនីយ៍ឯក **មាស ផេង** មេបញ្ជាការរង ផ្នែកសឹករងក្រុងកែប តំបន់ប្រតិបត្តិការសឹករងខេត្តកែប

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។ HSR

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៦៧. អនក្រ. បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ស្ពឺ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១០ រូប ដែលបានបរិច្ចាគកម្លាំងកាយចិត្ត និងធនធាន ចូលរួមកសាង សមិទ្ធផលផ្សេងៗ នៅវត្តត្រពាំងក្រពើ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- | លោក | **ថាច់ សែម** | សប្បុរសជន |
| ២- | ឧបាសិកា | **អ៊ឹង ស្មួយមួយ** | សប្បុរសជន |
| ៣- | លោក | **ឡាវ ម៉េងហុង** | សប្បុរសជន |
| ៤- | លោក | **អ៊ិន ឈុនយ៉ុង** | សប្បុរសជន |
| ៥- | លោក | **ជិន ស៊ិនហុង** | សប្បុរសជន |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- | លោក | **គុប សុន** | សប្បុរសជន |
| ២- | លោក | **ផាន់ ផេន** | សប្បុរសជន |
| ៣- | ឧបាសិកា | **ហៀង** | សប្បុរសជន |
| ៤- | លោកអាចារ្យ | **គុន ផាក** | គណៈកម្មការវត្ត |

៥- លោកអាចារ្យ **ចិន ម៉ុយ** គណៈកម្មការវត្ត

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ ០២ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដូចមាននាមខាងក្រោម ÷

១- លោក **ធូនី ព្រហ៊ីម**

២- លោក **អេល ម៉ាត់**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៦៤.អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃ កងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី **ជា ឆា** អត្តលេខ ០០៣៣៧៤ ជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បច្ចុប្បន្នទៅបំរើការងារក្នុងក្របខ័ណ្ឌ នគរបាលជាតិនៃក្រសួងមហាផ្ទៃ

២-ឧត្តមសេនីយ៍ត្រី **ជា ថា** អត្តលេខ ០១២៥៧៣ ជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បច្ចុប្បន្នទៅបំរើការងារក្នុងក្របខ័ណ្ឌ នគរបាលជាតិនៃក្រសួងមហាផ្ទៃ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តា សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការកំណត់តួនាទីភារកិច្ច និង រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាលក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** តែងតាំងមុខតំណែងមន្ត្រីរាជាការចំនួន ០២ រូប ក្នុងរចនាសម្ព័ន្ធអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាលក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោមៈ

១-លោក **មឿន សាម៉ន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ២ ជាអគ្គាធិការរង

២-លោក **ឈឹម គឹមលាង** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ជាអគ្គាធិការរង ។

**មាត្រា ២ :** ប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៥ រូប ក្នុងរចនាសម្ព័ន្ធអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាលក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម៖

១-លោក **សុខ លីនណា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ជាអគ្គាធិការរង

២-លោក **ហួ ផល្លា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ជាអគ្គាធិការរង

៣-លោក **ញ៉ែម សំអឿន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ ជាអគ្គាធិការរង

៤-លោក **ចែ សុខ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ជាអធិការ នៃអធិការដ្ឋានអធិការកិច្ច កិច្ចការនយោបាយ រដ្ឋបាល

៥-លោក **សូ សុផាន់ណា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ជាអធិការ នៃអធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនយោបាយ រដ្ឋបាល ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦៦ . អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងលោក **ហួយ សិទ្ធិសម្ភា** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៦៧-អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងលោក **ញ៉ូ ហេង** ជាទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៧៨.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៣ នាក់ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ជា ទុច** អត្តលេខ ០៤១៧

២- លោកវរសេនីយ៍ទោ **ឡោ សុខឡេង** អត្តលេខ ៥៤២៨០

៣- លោកវរសេនីយ៍ទោ **ឡាយ អុល** អត្តលេខ ០១៣៧៨ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៦៩ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
